# ព្រឹត្តិការណ៍រត់ឬជិះកង់តាមដងស្ទឹងសង្កែ

២០ មករា ២០២៤

បាត់ដំបង ប្រទេសកម្ពុជា




## ចូលរួមព្រឹត្តិការណ៍រត់ឬជិះកង់លើកដំបូង តាមដងស្ទឹងសង្កែ!

កំពុងស្វែងរកមហាព្រឹត្តិការណ៍រត់ ឬជិះកង់ផ្សងព្រេងរបស់អ្នកមែនទេ? ចូលរួមជាមួយកីឡាករកីឡាការិនីដែលមកពីជុំវិញទ្វីបអាស៊ី និងពិភពលោកសម្រាប់ការប្រណាំងនៅតាមបណ្តោយដងស្ទឹងសង្កែដ៏ស្រស់ស្អាតនាជាយក្រុងបាត់ដំបង ប្រទេសកម្ពុជា។ ព្រឹត្តិការណ៍នេះ គឺសម្រាប់អ្នករត់ទោល អ្នករត់ក្រុមបីនាក់ និងអ្នកជិះកង់ដែលចង់ប្រកួតប្រជែងលើផ្លូវផ្សងព្រេងជាមួយទេសភាពដ៏ស្រស់ត្រកាល ក្នុងគោលបំណងរួមចំណែកជួយកៀរគរមូលនិធិសម្រាប់សកម្មភាពសប្បុរសធម៌។

### ព័ត៌មានសង្ខេប

- កាលបរិច្ឆេទ៖ ២០ មករា
- ម៉ោង៖ ៥:៣០ ព្រឹក
- ចម្ងាយ៖ ៣០ គម
- ទីតាំង៖ បាត់ដំបង

### នរណាអាចចូលរួមបាន

- អ្នករត់ទោល៖ ៣០ គម
- អ្នកជិះកង់ទោល៖ ៣០ គម
- អ្នករត់ក្រុម ៣ នាក់៖ ម្នាក់រត់ចម្ងាយ ១០ គម

### ទីតាំងផ្លូវ

- ចាប់ផ្តើម៖ ប្រាសាទ បាណន់
- បញ្ចប់៖ បរិវេណសមាគម ហ្វារពន្លឺសិល្បៈ
- ផែនទីតាមវគ្គ៖ https://bit.ly/3udQUrj

## អំពីព្រឹត្តិការណ៍រត់ឬជិះកង់តាមដងស្ទឹងសង្កែ

ការប្រណាំងនឹងចាប់ផ្តើមនៅទីតាំងជើងភ្នំបាណន់ ដែលជាភ្នំដ៏ស្រស់ស្អាត មួយនៅជាយក្រុងបាត់ដំបង។ ទីតាំងផ្លូវមានខ្យល់បរិសុទ្ធ និងជាប់ដងស្ទឹងសង្កែ ឆ្លងកាត់វាលស្រែ ស្ពានចំណាស់ និងកាត់ក្រុងបាត់ដំបង ដែលជាទីក្រុងច្នៃប្រឌិតទទួលស្គាល់ដោយអង្គការយូណេស្កូនាពេលបច្ចុប្បន្ន។ អ្នកចូលរួមនឹងបញ្ចប់ការប្រណាំងនៅបរិវេណសមាគមហ្វារពន្លឺសិល្បៈហើយក៏ជាកន្លែងដែលអ្នកនឹងទទួលបានអាហារសម្រន់និងភេសជ្ជៈពីតូបលក់ដូរផងដែរ។

សម្រាប់អ្នកជិះកង់ ផ្លូវនេះគឺពិតជាសាកសម សម្រាប់ប្រភេទកង់ផ្លូវ និងកង់ឡើងភ្នំ ដែលនឹងធ្វើដំណើរតាមផ្លូវស្រដៀងនឹងអ្នករត់ផងដែរ។ ក្រុមការងារនឹងផ្តល់ជូនការដឹកជញ្ជូនកង់របស់បេក្ខជនទៅកាន់ទីតាំងចាប់ផ្តើម។

អ្នករត់ទោល និងអ្នកជិះកង់គួរមានសមត្ថភាពអាចរត់ឬជិះបានយ៉ាងហោចណាស់ពាក់កណ្តាលម៉ារ៉ាតុង ដែលស្មើរនឹង២១គម។ ចំនែកឯអ្នករត់ក្រុមតត្រូវរត់ចម្ងាយ១០គម ក្នុងមួយនាក់។ ប្រសិនបើអ្នកចូលចិត្តរត់ ឬជិះកង់ផ្លូវឆ្ងាយ ការប្រណាំងមួយនេះគឺពិតជាល្អឥតខ្ចោះសម្រាប់អ្នក។

# អំពីអ្នករៀបចំព្រឹត្តិការណ៍

ហ្វារពន្លឺសិល្បៈ Phare Ponleu Selpak

ហ្វារពន្លឺសិល្បៈ Phare Ponleu Selpak (PPS) គឺជាសាលាសិល្បៈកម្ពុជាមិនស្វែងរកប្រាក់ចំណេញដែលមានទីតាំងនៅខេត្តបាត់ដំបងដែលធ្វើការពង្រឹងអំណាចដល់កុមារ យុវជន និងសហគមន៍តាមរយៈកម្មវិធី សិល្បៈអប់រំគាំទ្រសង្គម។ ដោយទទួលបានការបំផុសគំនិតពីសិក្ខាសាលាគូរគំនូរនៅជំរុំជនភៀសខ្លួន សាយធូតាមបណ្តោយព្រំដែនកម្ពុជា-ថៃ សិស្សជម្លៀសខ្លួនចំនួនប្រាំបួននាក់បានរួមគ្នាបង្កើតសមាគមហ្វារពន្លឺសិល្បៈក្នុងឆ្នាំ ១៩៩៤ នៅជាយក្រុងបាត់ដំបង។ មានសិស្សជាង ១០០០ នាក់បានចូលរួមក្នុងសកម្មភាពសិល្បៈ និងវប្បធម៌ប្រចាំថ្ងៃដោយមិនគិតថ្លៃ។ ថ្នាក់សិក្សា និងសិក្ខាសាលារួមមាន៖ តន្ត្រី របាំ សិល្បៈសូនរូប ល្ខោនសៀក គំនូរជីវចល និងការរចនាក្រាហ្វិក។ ហ្វារពន្លឺសិល្បៈផ្លាស់ប្តូរជីវិតតាមរយៈសិល្បៈដោយផ្តល់ឱ្យសិស្សនូវឱកាសដើម្បីក្លាយជាសិល្បករនិងអ្នកសំដែងឯករាជ្យដ៏មានជំនាញវិជ្ជាជីវៈ។



## មូលហេតុបានជាយើងរៀបចំការរត់ដងស្ទឹងសង្កែ

រួមចំណែកអបអរ **ខួប ៣០ ឆ្នាំ** នៃហ្វារពន្លឺសិល្បៈ

និង កៀរគរមូលនិធិ **៣០០,០០០ ដុល្លារ** សម្រាប់កម្មវិធីសិល្បៈ និងអប់រំ

## ត្រៀមខ្លួនដើម្បីទទួលយកការប្រកួតប្រជែងមួយនេះហើយឬនៅ?

### ១. ត្រៀមខ្លួន

ចុះឈ្មោះដោយប្រើកូដ QR ខាងក្រោម។ ចុះឈ្មោះមួយក្នុងចំណោមក្រុមខាងក្រោម៖

- អ្នករត់ក្រុមបីនាក់ ១០ គម
- អ្នករត់ទោល ៣០ គម
- អ្នកជិះកង់ទោល ៣០ គម

### ២. ទទួលការកំណត់

កៀរគរមូលនិធិពីក្រុមគ្រួសារ មិត្តភ័ក្តិ និងសហការីរបស់អ្នក។ កញ្ចប់មូលនិធិដែលមានព័ត៌មានលម្អិតនឹងត្រូវបានផ្ញើរទៅអ្នក (ឬក្រុមរបស់អ្នក) បន្ទាប់ពីការចុះឈ្មោះរួច។

### ៣. ប្រណាំង!

យើងទន្ទឹងរង់ចាំជួបអ្នកនៅឯព្រឹត្តិការណ៍រត់តាមដងស្ទឹងសង្កែ។ ក្រោយមកដល់គោលដៅ នាពេលរសៀលសូមរីករាយជាមួយនឹងការសម្តែងសៀកដោយឥតគិតថ្លៃពីសិស្សានុសិស្សរបស់យើង។

## ព្រឹត្តិការណ៍រត់ឬជិះកង់តាមដងស្ទឹងសង្កែ

៣០ គម សម្រាប់ ៣០ឆ្នាំ
នៃសមាគមហ្វារពន្លឺសិល្បៈ

២០ មករា
២០២៤

ចុះឈ្មោះរត់ ឬជិះកង់៖

ហ្វារពន្លឺសិល្បៈ Phare Ponleu Selpak

phareps.org